LY
រូបភាព

I.S.R.C

ខ្នទាំងអស់

និពន្ធដោយ. ឃឹម.សាវ៉ន. វិចិត្រករ. ដោយ
សោម. សុខុន. ឃិន. ឈុន. ជី.

ពិនិត្យដោយ គណៈកម្មការមជ្ឈមណ្ឌល
ពង្រីកការអប់រំខ្មែរ ស្រះកែវ

SAKAEO E.D.C.

ឧបត្ថម្ភ និង បោះពុម្ពផ្សាយដោយ អង្គការ
សូតូហ្សុ ជប៉ុន

ពេលមួយ ពូ ប៉ូចនិងកូនប្រុសឈ្មោះ ម៉ាប់ ដោយការ
ទីទ័លក្រពេក ក៏ហៅអាម៉ាប់ជាកូន មកពិភាក្សាថា៖
អាម៉ាប់កូន ! យើងសព្វថ្ងៃទីទ័លក្រខ្លាំងណាស់ បានព្រឹកខ្វះល្ងាច បានល្ងាចខ្វះព្រឹក ផ្ទះក៏ទ្រុឌទ្រោមស្លែកល្អុយអស់ទៅហើយ ។

ពេលភ្លៀងម្ដងៗរកកន្លែង គត់មត់គ្មាន តើយើងធ្វើ យ៉ាងម៉េចរាម៉ាប់ ?
ពុកអើយ! នេះ ហេតុតែយើងក្រ សំលៀកបំពាក់ក៏ មិនសមរម្យនឹង គេ

អើ ឥឡូវពុកថានឹង យកកូនលា
ស្ករនេះទៅលក់ គ្រាន់បានទិញនេះ
ទិញនោះណាកូន តើឯងថាម៉េច ?
លក់ក៏លក់ចុះ
ពុក
អើ ព្រឹកនេះយើងចេញទៅលក់ឯស្រុកឆ្ងាយ ៗ ក្រែងបាន
កម្រៃគ្រាន់ ៗ តែរវាម៉ាប់កូន ដើម្បីកុំអោយលាស្រេក
សាច់ក្នុងការធ្វើដំណើរផ្លូវឆ្ងាយ កូនឯងនិងពុកត្រូវតែ
សែងលានេះ

ព្រឹកឡើងឪពុកនឹងកូន ប្រុងចងលាសែកអាម៉ាប់ និយាយថា:
ពុកវង់តូចដាក់ខ្ញុំ សែងដើរខាង មុខខ្ញុំ
សែងទៅបានបន្តិចជួបនឹងអ្នកដំណើរៗ និយាយថា:
ម្នាលអ្នកកំឡៅទាំងពីរ សត្វលាជាជំនិះ គេតែងតែជិះ ហេតុម្តេចបានជាអ្នកនាំគ្នាសែងទៅវិញ ល្ងង់អីក៏ល្ងង់ម្ល៉េះ ?

អាចាប់កូនឬទេ? បើអញ្ចឹងឯងជិះ ខាងមុខអញ ៗ ជិះខាងក្រោយ
ឪពុក! មកដល់វត្តនេះ គេហៅវត្តអ្វីពុក ?
មិនដឹងទេកូន តែមានឧបា- សក ឧបាសិ កា ច្រើន ណាស់

អើ! អ្នកជិះលា ធ្វើដំណើរទៅឯណា
អពោះលោកអើយ កូនលាប៉ុណ្ណឹងព្រួតគ្នាជិះ មិនអាណិតគ្នាយ៉ាងនេះ។ មិនស្លាប់គ្នាទេ ឬអី?
អាម៉ាប់ ឬទេអាម៉ាប់?
ឬ ហើយឬក៏
6

ពុកឯងចាស់ជាងខ្ញុំ ពុកឯងជិះទៅ ទុកខ្ញុំ ដើរតាមក្រោយ កុំ អោយគេថា ទៀត...
អើ អញ្ចឹង ក៏បាន...
បើ ពុកក្រាន់នេះ អ៊ី អរម្ល៉េះ គេ មានការ អ្វី ?...
ទេកូន ទីនេះអណ្តូង ទីកន្លែងស្រីក្រមុំៗ គេដងទឹកណា៎

ទៅសុំទឹកគេផឹកសិន ពុក
ឪអ៊ី! តាជិះលា ក្ដូ លាស្គាវនេះ មានរូបរាងស្អុតណាស់ មិនសមតាឯងជិះទេ សមតែអ្នកកម្លោះ គោះដែលដើរពីក្រោយ ជិះទើបសមនឹង លាស្គាវនេះ
ណុរសី

ខទៀតហើយ
អាម៉ាប់ ដង់ដើរម្តងវិញ
ទៅ ពុកដើរដឹកម្តង
ចុះមកដល់ភូមិនេះ
គេគាំគ្នាស៊ីអីទៀតហើយ
ពុក
គេនាំគ្នាដឹកស្រះ
ណាំ

អើអ្នកកម្លោះជិះលា អ្នកឯងមានសាច់ច្រើនកម្លាំងមាំទាំ គួរណាស់ទៅហ្ន ដែលអោយមនុស្សចាស់កម្លាំងថមថយដើរដឹកលាទៅវិញ គ្មានដឹងបាបបុណ្យគុណទោសអ៊ីយ៉ាងនេះ

ឱ!
រកមាច់កូនអើយ
ខុសទៀតហើយ មកចុះ
ដើរដឹកវិញ
ពុកឯងដើរដេញពីក្រោយចុះ
ខ្ញុំដើរដឹកពីមុខ
Oooooo.....

ឱ ! ពុកអើយ ចំណាង់បើព្រះអាទិត្យព្រះចន្ទ ដែលតែងតែបំភ្លឺពិភពលោកជាធម្មតា នៅមិនត្រូវចិត្តមនុស្ស អាចារ្យតែចេះ និង អាចារ្យតែចាំ គ្មានដែលខុសទេ គេត្រូវទាំងអស់ មិនដឹងជានឹងផ្គាប់ចិត្តលោកណាអោយត្រូវទេ ។


ISRC

ការចូលរួម

ចិនដោះឃ្មី

និពន្ធដោយ ជា កែម

គូរដោយ ឃិន ឈុនលី

ឧបត្ថម្ភបោះពុម្ពដោយ

JSRC

កាលពីព្រេងនាយ មានកុមារម្នាក់ មានប្រាជ្ញាវាងវៃ ថែមទាំងមានល្បិចកលខុចទៀតផង អ្នកភូមិតែងហៅវាថា "អាគុជកល"។

កុមារគុជកលរស់នៅកំព្រាតែម្នាក់ឯង ។ វាមានគោមួយជាកេរ្តិ៍មត៌កពីខ្មោចឪពុកម្តាយ ។

2

ថ្ងៃមួយមិនដឹងជាចង្រៃចៃដន្យអ្វី ស្រាប់តែមេគោសំណាប់
របស់វា ស្លាប់ខ្លួនរឹងក្រញ៉ង់ ដេកស្តូកស្តឹងក្នុងក្រោល ។
វាអស់សង្ឃឹមជាខ្លាំង ។



តែវាបានព្រលះ យកសាច់ទៅលក់ និងរកបរិភោគខ្លះព្រមទាំង ស្បែកមេគោភាហាលស្ងួត ហើយសង្ឃឹមថានឹងបានយកទៅ លក់ឯទីផ្សារ គ្រាន់បានកម្រៃខ្លះសម្រាប់បន្តជីវិត ។

កាលបើហាលស្បែកគោស្ងួតស្រួលបួលហើយ វាក៏បត់វេច ស្រេចបាច់ ទើបទូលដើរចេញពីផ្ទះតម្រង់ទៅផ្សារ ។ ប៉ុន្តែនោះ វាខំដើរលក់យ៉ាងណាក្តី ក៏ពុំមាននរណាម្នាក់ទិញឡើយ ។ ម្លោះហើយ វាត្រូវដើរកាត់ព្រៃ ឆ្លងភ្នំ ដើម្បីយកទៅលក់នៅ ស្រុកផ្សេងៗទៀត

4

នៅពេលយប់មួយ ដោយហេវហត់ក្នុងដំណើរខ្លាំងពេក វាក៏ឡើងសម្រាកកម្លាំងលើដើមឈើមួយដ៏ធំ ។ វាទើបតែភ្លេចភ្នែកទៅហើយ ដោយក្តីងោកងុយ ៗ ស្រាប់តែឮសូរសន្ធឹកជើងសេះដំរង់មក ចំដើមឈើដែលវាលាក់ខ្លួន ៗ

វាភ័យខ្លាំង ៗ

វាបានមើលឃើញ ចោរពីរនាក់កំពុងតែចាក់មាស ពេជ្រជាច្រើនចេញពីក្នុងថង់ដើម្បីចែកគ្នា ។



(៦)

នៅពេលនោះ កុមារគូជខិល បានឃើញហើយភិតភ័យញ័រខ្លួន ចំប្រប់ រហូតរបូតធ្លាក់ដុំស្បែក ដែលស្ងួតរឹងវិស័យ ដុំធ្លាក់ ចុះចំកណ្តាលវង់ពួកចោរ ៗ

ចោរទាំងពីរ កាលបើឃើញយ៉ាងនេះ នឹកស្មានថា មាន
ហេតុអាក្រក់កើតដល់ខ្លួន ទើបភ័យស្លន់ស្លោ ដើររត់
ប្រាស់អាយុកែរៀងខ្លួន ចោលមាសពេជ្រទាំងអស់ ។

(៤) ឯចំណែក កុមារគុចរិស ពេលដែលចោរ ឡានរត់គេចបាត់អស់ទៅ ក៏ស្ទុះរះចុះពីលើដើមឈើ ប្រមូលយកសម្បត្តិចោរទាំងអស់ត្រឡប់ទៅផ្ទះវាគ្នាវិញហោង ។

១

ចំណោរកាលមកកុមារតូចវិស ក៏ឡើងឋានៈជាអ្នកមាន ទ្រព្យស្តុកស្តម្ភ វាមានឈ្មោះល្បីល្បាញរន្ទឺខ្ទរខ្ទារ ទូទាំងប្រទេសរហូតលេចឮទៅដល់ស្តេចផែនដី ។

10

ពេលនោះដូនជាប្រទេសត្រូវសេដ្ឋកិច្ចចុះដុនដាបជាខ្លាំងៗ តាំងស្ដេចតាំងមន្ត្រី ពុំអាចរកមធ្យោបាយអ្វីមកស្តារសេដ្ឋកិច្ចបានឡើយ ។ ស្ដេចបានប្រកាសរកអ្នកជំនាញការ ដើម្បីជួយធ្វើឲ្យបានប្រាក់ច្រើនចូលឃ្លាំងៗ ដោយលេចឮថា កុមារតូចវិសេសអាចរកទ្រព្យសម្បត្តិបានដោយស្រួល ទើបព្រះអង្គទ្រង់បញ្ជាឲ្យអាមាត្យទៅកោះហៅកុមារតូចមកជួប ព្រះអង្គដើម្បីសួរពត៌មានផ្សេងៗ អំពីរឿងនេះ ។

11

នៅចំពោះព្រះភក្ត្រ មហាក្សត្រ វានិយាយកុហកថា វាបាន
សម្លាប់មេគោដែលវាចិញ្ចឹមដើម្បីយកស្បែកទៅលក់
ហើយក៏បានយកប្រាក់នេះទៅរកស៊ី លុះបានចំរើនទ្រព្យដូច
សព្វថ្ងៃ ។



កាលបើទ្រង់បានសណ្ដាប់ដូចនោះហើយ ព្រះអង្គក៏ចាត់ឱ្យអាមាត្យសម្លាប់គោដែលជារាជទ្រព្យទាំងហ្វូងៗ ដើម្បីយកស្បែក រួចបានចាត់នាយឃ្លាំងឱ្យដើរចេញដួញតាមពាក្យកុមារវិលភូច ។

ជំនួញបែបនេះពុំបានសម្រេចផលឡើយ ។ ទើបអាមាត្យ
ព្រាចទាំងនាយឃ្លាំង នាំគ្នាចូលទៅគាល់ស្តេច ដើម្បីឱ្យទ្រង់
បានជ្រាប ពីកិច្ចការ ទាំងនេះ ។ ស្តេចទ្រង់ពិរោធយ៉ាងខ្លាំង
ម្យ៉ាងដោយព្រះអង្គត្រូវបានហិនហោចអស់ ទ្រព្យាងគោ
ជាភាគច្រើន ម្យ៉ាងដោយកុមារខិលខូច បានកុហកដល់ព្រះ
អង្គជាស្តេចផែនដី ។

14

ទ្រង់តំរិះយ៉ាងនេះទើបត្រាស់ទៅអាមាត្យឱ្យចាប់ចងកុមារ
ដាក់ក្នុងបាវយកមកថ្វាយទ្រង់ដើម្បីធ្វើទារុណកម្ម ។



មកដល់ពាក់កណ្តាលផ្លូវ ដោយធ្ងន់ពេក និងអស់កម្លាំង
ផង ពួកអាមាត្យ បានដាក់បាវទុកចោលនៅមាត់ផ្លូវ ហើយ
នាំគ្នាចូលទៅបរិភោគបាត់ទៅ ។



16
ពេលនោះកុមារតូចវិល បានបែកបាវមើលឃើញ
អ្នកគង្វាលចៀមដើរមកជិតវា ។ វាក៏ស្រែកហៅបុរសនោះ
ទៅជិត ហើយអង្វរករថា សូមអ្នកជួយស្រាយមាត់បាវ
ឱ្យខ្ញុំផង ។ ខ្ញុំត្រូវស្តេចចាត់ឱ្យគេចាប់យកទៅក្នុងវាំង
ដើម្បីទ្រទ្រង់ក្នុងការបង្ហាត់សេះ
និងដំរីក្សត្រ
ទ្រព្យតែខ្ញុំ ពុំសូវចង់
សោះ ព្រោះខ្ញុំមានទម្លាប់
ខ្លាចសេះណាស់ ។
ដោយខ្ញុំប្រកែកខ្លាំង
ពេក ក៏ត្រូវពួកអា
មាត្យ ចាប់ច្រកបាវ
បែបនេះ ។

អ្នកគង្វាលចៀម ដោយសេចក្ដីល្មោបបុណ្យស័ក្ដិ ក៏មាន
ជំនឿរស្អុងក្នុងចិត្ត ។ នាយគង្វាលអារក្រួច គិតក្នុងចិត្តថា៖
" អាក្មេងនេះពិតជាល្ងង់ណាស់ អាត្មាអញមានលាភហើយ
តើ! គួរអីអញនៅ ដើរឃ្វាលចៀមយ៉ាងនេះ"

18

គិតហើយអ្នកគង្វាលចៀមក៏ស្រាយមាត់បាវឱ្យកុមារចិល
ចេញ រួចខ្លួនឯងចូលជំនួសវិញ ។



អាមាត្យកាលបើបាន សម្រន់ក្រពះរួចរាល់ហើយ
ក៏ចាប់លើកបាវសីបន្តដំណើរទៅទៀត ដោយរតតដីវ
ស្រុះព្រឹត្តិ ហេតុអ្វីឡើយ

20)

គ្រាន់តែទៅដល់ភ្លាម ស្តេចក៏បញ្ជាឱ្យបរអាមាត្យ យកដាវនោះទៅទម្លាក់ទឹកទន្លេទៅ ។ ឯអ្នកគង្វាលចៀមក៏ស្លាប់អាសារតតការទៅហោង ៕



កន្លងមកពុំយូរប៉ុន្មាន ស្ដេចបានឃើញកុមារតូចវិលនៅតែរស់ដដែល ហើយថែមទាំងមានហ្វូងចៀមជាច្រើនជាសម្បត្តិផង ។ ស្ដេចឆ្ងល់ខ្លាំងណាស់ ក៏ត្រាស់ហៅកុមារមកសួរថា៖ " តើឯងបានហ្វូងចៀមនេះពីណាមក ? វាឆ្លើយថា៖ " សូមទ្រង់ព្រះមេត្តាប្រោសចៀមទាំងនេះ កាលខ្ញុំព្រះករុណាធ្លាក់ទៅបាតទន្លេបានឃើញហ្វូងចៀមទាំងនេះ រួចក៏ប្រមូលកៀងគេយកមក » ។

22

ឯស្ដេចក៏ទ្រង់ជឿរដោយឥតសង្ស័យ ។ ដោយមានព្រះទ័យចង់បានសម្បត្តិច្រើន ព្រះអង្គទ្រង់ត្រាស់បញ្ជាឱ្យអាមាត្យចាប់ព្រះអង្គ ច្រកក្នុងបាវដូចកាលព្រះអង្គចាត់ឱ្យធ្វើលើកុមារភូធខិល ។

ចាប់ពីថ្ងៃនោះមក គេពុំដែលឃើញស្ដេចទៀតឡើយ ។



សៀមទក្រាង

រដាយរ រូបភាព

ក្បឹក្រមពីកំហាប់សក្ដិ

ខ្ញុំពាក់ក៏កាត់

វិចិត្រករដោយ ញឹក.សុខ

សរសេរអក្សរដោយ.សោម.សុខុន

ពិនិត្យដោយមជ្ឈមណ្ឌលពង្រីកការរបស់ខ្មែរ(E.D.C.)

ឧបត្ថម្ភ និងបោះពុម្ពផ្សាយដោយ

អង្គការ សូតូហ្ស ជប៉ុន (J.S.R.C.)

លំ

ម្ន

ដ

“ក្

ប្

កំ

ចូល

ចេ

ឯស្

ទៅ

ទោ

ស្តេច

អំបែ

កាល ពីព្រេងនាយ មានបុរសម្នាក់កំសត់ក្រលំបាក ម្តាយឪពុកស្លាប់ចោលតាំងពីតូច នៅតែម្នាក់ឯង តែងរកស៊ីចិញ្ចឹមអាត្មាគ្រាន់តែឆ្អែតពោះ ។ ដល់បុរសនោះចំរើនធំដឹងសេចក្តីឡើង ក៏ចង់ដឹងថាៈ “ក្នុងនគរនោះ នឹងមានស្ត្រីពិត ម្តាយពិត ឪពុកពិតឬទេ ”។ ថ្ងៃមួយស្តេចក្នុងនគរនោះ ទ្រង់គិតធ្វើបុណ្យកំសាន្តសប្បាយមួយ ។

ស្តេចទ្រង់មានព្រះបន្ទូលហៅនាហ្មឺនធំម្នាក់ អោយចូលមកគាល់ ។ មកដល់ទ្រង់បង្គាប់អោយនាហ្មឺននោះចេញទៅធ្វើរោងសង់សាលាបុណ្យ នៅត្រើយស្ទឹងម្ខាង។ ឯស្ទឹងនោះមានស្ពានស្ម ឆ្លងទៅ ។ នាហ្មឺននោះ ទៅសង់រោងសាលារួចស្រេច វិលមកក្រាបទូលស្តេច ស្តេចទ្រង់អោយរៀបផ្កាភ្ញី ស្លាម្លូ គ្រប់បរិក្ខា ជារណ្តាប់បុណ្យហើយស្តេចយាងចេញទៅកាន់ចុងព្រះរាជវាំង ដោយជួបជុំមុខមន្ត្រីតូចធំហែរហម ស្តេចយាងចូលរោងបុណ្យ ។



ឯបុរសនោះ ឮថាស្ដេចធ្វើបុណ្យដូច្នេះ ក៏មានសេចក្ដីត្រេកអរ ដោយចង់ដឹងថា: " ក្នុងនគរ នោះមានស្ត្រីពិត ម្ដាយពិត ឪពុកពិតឬទេ? " ហើយបុរស ដើរទៅអង្គុយក្រោមស្ពាន ធ្វើជាស្ទូចត្រី ។ ស្ដេចទ្រង់យាងទៅឯសាលាបុណ្យមុនគេ នៅតែអស់អ្នកនិងព្រះរាជបុត្រីស្ដេច ។ ដល់វេលារសៀល អស់អ្នកនិងព្រះរាជបុត្រីស្ដេចនោះ រៀបខ្លួននឹងទៅចូលរោងបុណ្យ ឯព្រះរាជបុត្រីស្ដេចនោះ កំព្រាពុំមានព្រះមាតាៗ ក្ស័យព្រះជន្មចោលនាង តាំងពីតូចម្ល៉េះ លុះអស់អ្នកនិងពួកស្រីស្នំក្រមការឆ្លងហួសអស់ទៅ នៅតែព្រះរាជបុត្រីកំព្រាជាក្រោយគេ ដល់នាងយាងទៅដល់ស្ពាន នាងទតឃើញបុរសកំសត់អង្គុយស្ទូចត្រីនៅក្រោមស្ពាន នាងឈប់ ពុំហ៊ានយាងហួសទៅ អស់ពួកស្រីបរិវារសួរថា: " ម្ចាស់ស្ត្រីដូចម្ដេចបានជាឈប់? " ។ ទើបនាងមានព្រះសវនីយ៍ប្រាប់អស់ពួកស្រីៗថា: " បានជាខ្ញុំឈប់ ត្បិតមានបុរសម្នាក់នៅអង្គុយស្ទូចត្រីក្រោមស្ពាន ទៅដូចម្ដេចនឹងបាន " ។



អស់ស្រីសារទ្រ៉ឹកថា៖ " ម្ចាស់យាងទៅមិនរវីទេ ខ្លាចថ្វីមនុស្សកំសត់ដូចមនុស្សឆ្កួត " ។ នាងឆ្លើយឡើងថា៖ " កុំស្រែកដូច្នោះមិនត្រូវទេ ធម្មតាគេជាប្រុស ទុកជាគេឆ្កួត ព្រើលល្ងង់ខ្លៅ ដូចម្តេច ក៏យើងជាស្រី មិនត្រូវដើររំលងក្បាលគេទេ " ។ អស់ពួកស្រីៗវាស្តីអោយថា៖ " នែអ្នកកម្លោះអន្ទុយស្ទួចត្រីក្រោមស្ពានដើរចេញម្ចាស់យើងយាងទៅធ្វើបុណ្យ " ។ បុរសនោះឮស្រីស្រែកថាដូច្នោះ ក៏មិនដើរចេញធ្វើជាមិនឮ ។ ឯនាងបុត្រីស្តេចក៏ស្រែកទៅបុរសនោះថា៖ " នែអ្នកស្ទួចត្រី អញ្ជើញចេញពីក្រោមស្ពានទៅ អោយខ្ញុំសុំផ្លូវទៅផង " ។ បុរសនោះឮនាងបុត្រីស្តេចនិយាយដូច្នោះ ក៏ក្រោកដើរចេញតយង៉យទៅផ្ទះវាត្រាវិញ ។ ឯនាងបុត្រីស្តេចឃើញថាបុរសនោះដើរហួសទៅ ទើបនាងបានឆ្លងទៅធ្វើបុណ្យជាមួយនឹងស្តេចជាឪពុក ដល់ពេលធ្វើបុណ្យរួចស្រេចបរិបូណ៌ ស្តេចក៏វិលមកព្រះរាជដំណាក់វិញ ។



លុះថ្ងៃក្រោយ បុរសនោះគិតក្នុងចិត្ត នឹកចង់ចូលទៅគាល់ស្តេច ក៏រៀបខ្លួនតាមដោយខ្លួនជាអ្នកក្រលំបាក រៀបរួចចេញដើរពីផ្ទះអាត្មាទៅ ដល់មាត់ទ្វារវាំងក៏ចូលទៅដោយបំណងនឹងគាល់ស្តេច ។ ឯពួកទាហានចាំទ្វារវាំងឃាត់មិនអោយចូលថា: " ចៅបុរសឯង រូបក៏អាក្រក់ សំពត់ក៏ចាស់ដាច់ដាច មិនគួរនឹងចូលក្នុងវាំងស្តេចទេ " ។

បុរសនោះគិតក្នុងចិត្តថា: " អញគិតធ្វើដូចម្តេច អោយបានក្រាបដល់ស្តេច ។ នឹងហៅអញចូល " ។ ហើយនិយាយទៅនឹងពួកទាហានចាំទ្វារវាំងថា: " អ្នកកុំឃាត់ខ្ញុំ ត្បិតខ្ញុំឃើញនគរស្តេច ឥតមានស្ត្រីពិត ម្តាយពិត ឪពុកពិតទេ " ។ ចៅបុរសនោះ និយាយតែប៉ុណ្ណោះ ក៏អង្គុយស្ងៀមនៅនឹងមាត់ទ្វារនោះទៅ ពុំនិយាយស្តីនឹងអ្នកឯណាទៀតឡើយ ។ លុះស្តេចចេញកាន់ព្រះរាជវាំង អស់នាម៉ឺនតូចធំមកជួបជុំគ្នាគាល់ស្តេច ។

នាយទាហានចាំទ្វារវាំងសង្ស័យណាស់ ក៏ចូលទៅក្រាប់ទូលស្ដេចថា: " មានចៅប្រុសកំសត់ម្នាក់ មកពីណាមិនដឹង ចង់ចូលមកគាល់ព្រះអង្គ ទូលបង្គំជាខ្ញុំឃាត់មិនអោយចូល ត្បិតបុរសនោះស្លៀកសំពត់ដាច់ដាចលេចមុខលេចក្រោយ តែចៅប្រុសនោះនិយាយជាមួយទូលបង្គំជាខ្ញុំថា: " អ្នកឯងមិនត្រូវឃាត់ខ្ញុំទេ ត្បិតខ្ញុំយល់ឃើញថា: ក្នុងនគរនេះគ្មានស្រីពិត ម្ដាយពិត ឪពុកពិតទេ " ។ ចៅប្រុសនោះនិយាយតែប៉ុណ្ណោះក៏នៅស្ងៀមទៅ ។ ស្ដេចទ្រង់ជ្រាបដូច្នេះ ទ្រង់សួរទៅនាយទាហានថា: " ចុះឥឡូវចៅប្រុសនោះនៅឯណា?

នាយទាហានចាំទ្វារទូលថា: " នៅឯមាត់ទ្វារវាំងក្រាបទូល " ។ ទើបស្ដេចមានព្រះបន្ទូលថា: " បើដូច្នោះអាមាត្យឯងទៅហៅវាមកមើល " ។ អាមាត្យរត់ទៅហៅបុរសអង្គុយនៅមាត់ទ្វារប្រាប់ថា: " នែ៎ចៅប្រុស ស្ដេចមានព្រះបន្ទូល-អោយចៅប្រុសឯងចូលទៅ " ។



ចៅបុរសនោះ ក៏ដើរទៅជាមួយនឹងអាមាត្យ ទៅដល់ហើយ ក្រាបថ្វាយបង្គំស្តេចហើយអង្គុយគាល់ក្នុងទីដ៏សមគួរទៅ

ស្តេចទតឃើញអាមាត្យនាំចៅបុរសនោះមកគាល់ ទ្រង់មានបន្ទូលថា: " ចៅបុរសឯងនិយាយថា: ក្នុងនគរអញនេះ គ្មានស្ត្រីពិត ម្តាយពិត ឪពុកពិតទេ តើចៅបុរសឯងថាដូច្នោះមែនឬដូចម្តេច? " ។ ចៅបុរសនោះក្រាបទូលថា: " សូម, ទ្រង់ព្រះមេត្តាប្រោស ក្នុងទីព្រះនគររបស់ល្អងធូលីព្រះបាទនេះ គ្មានស្ត្រីពិត ម្តាយពិត ឪពុកពិតទេ ទូលព្រះបង្គំជាខ្ញុំថាមែន ក្នុងទីព្រះរាជវាំងមានតែញី ទូលព្រះបង្គំជាខ្ញុំថាមែន, ម្តាយពិត ឪពុកពិតគ្មាន ទូលព្រះបង្គំជាខ្ញុំថាមែន " ។ ចៅបុរសទូលតបទៅនឹងស្តេចទៀតថា: " សូមទ្រង់ព្រះមេត្តាប្រោស ឯស្ត្រីពិតមានតែមួយ ដែលជាព្រះរាជបុត្រីពៅព្រះករុណាថ្លៃវិសេសនេះ ទើបហៅស្ត្រីគបនរលក្ខណ៍ជាក់ជាស្ត្រីពិតមែន ។

ស្តេចទ្រង់យល់ដូចចៅបុរសគោះថាមែន ទើបមានព្រះ
បន្ទូលសួរថាៈ « នែចៅបុរស! ដូច្នេះម្តេចហៅថាស្ត្រីពិត?
ដូចម្តេចហៅថាម្តាយពិត ឪពុកពិត? » ចៅបុរសក្រាប
ទូលស្តេចថាៈ « សូមទ្រង់ព្រះមេត្តាប្រោស ឯស្ត្រីពិត ម្តាយ
ពិត ឪពុកពិតនោះ មានតែស្បង់ធូលីព្រះបាទ យាងចេញ
ពីព្រះនគរ ទៅស៊ើបរកស្គាល់ព្រះវត្តទើបបាន បើស្បង់ធូ-
លីព្រះបាទរកបាននៅទីណា ស្រុកណា ភូមិណា សូមស្បង់
ធូលីព្រះបាទទ្រង់ត្រិះតាមព្រះរាជហឫទ័យ ដែលទ្រង់គិត.
បើញុំដូចម្តេច សុះទ្រង់ពិសោធន៍គ្រប់ចំពូកទៅហើយពុំមាន
អ្វី ទើបហៅពេញថាស្ត្រីពិត ម្តាយពិត ឪពុកពិត » ។
ស្តេចទ្រង់ជ្រាបសព្វគ្រប់ប្រការ ទ្រង់នឹកក្នុងព្រះចិន្តាថាៈ « ចៅ-
បុរសនេះនិយាយត្រូវប្រាកដ ហើយទ្រង់ព្រះរាជទានមាសប្រាក់
សំពត់អាវ អោយចៅបុរសនោះទ្រង់ផ្តាំថាៈ « ចៅបុរសឯង កុំទៅ
ណាឆ្ងាយ នៅចាំអញ បើអញរកស្ត្រីពិតម្តាយពិតឪពុកពិតបាន
ហើយ អញនឹងមកវិញថ្ងៃណា អញនឹងអោយចៅបុរសឯង ត្រិះ
លើគេទាំងពេល » ។

ហើយស្តេចទ្រង់អោយនាហ្មឺនធំម្នាក់ ធ្វើផ្ទះមួយអោយចៅបុរសនោះនៅ ទ្រង់ផ្តាំនាហ្មឺននោះថា: អោយដប់ល្បៀងចិញ្ចឹមចៅបុរសនោះតរៀងទៅ ។ ក្នុងពេលដែលស្តេចទ្រង់យាងចេញចាកនគរ ទៅរកស្ត្រីពិត ម្តាយពិត ឪពុកពិត នោះស្តេចមានបន្ទូលហៅនាហ្មឺនធំម្នាក់ ដែលជាអ្នកសម្រេចរាជការក្នុងព្រះនគរ អោយមើលរក្សាព្រះរាជវាំង ត្បិតទ្រង់នឹងយាងចេញរកស្ត្រីពិត ម្តាយពិត ឪពុកពិត ហើយទ្រង់រៀបដំណើរក្លែងព្រះអង្គជាបុរសកំសត់ម្នាក់ យាងចេញទៅក្នុងវេលាយប់ស្ងាត់ ពុំអោយនរណាមួយដឹងឡើយ អោយដឹងតែបុត្រីដែលជាធំ នឹងចៅបុរសនោះប៉ុណ្ណោះ ហើយស្តេចយាងទៅធ្វើជាបុរសកំសត់ក្រលំបាក ពុំអោយអ្នកណាស្គាល់ជាស្តេចឡើយ ។ ស្តេចយាងទៅដល់ស្រុកមួយជាព្រំព្រះនគរ ឃើញតាចាស់យាយចាស់ ស្តេចក៏ចូលទៅសុំសំណាក់នៅផង ។ ជូនតានោះក៏ព្រមអោយនៅ ដល់នៅយូរបន្តិចទៅ ឃើញកូនគេក្នុងស្រុកនោះ មានរូបឆោមលោមពណ៌ល្អ ក៏មានចិត្តនឹកចង់បាន **ទើបនិយាយនឹងតាយាយថា:**



តាយាយអើយ ឥឡូវចៅ ឃើញកូនគេមួយ រូបឆោម លោមពណ៌ល្អសមជាប្រពន្ធ ខ្ញុំ ដូច្នេះសូមតាយាយ ទៅដណ្តឹងអោយខ្ញុំ ។
ឱ ចៅអើយ! ឥឡូវតាសព្វ ថ្ងៃនេះ ជាអ្នកកំសត់អត់ឃាន ក្រលំបាកណាស់ នឹងទៅ ដណ្តឹងកូនគេ តើនរណា គេនឹងអោយ ។

ស្ដេចប្រាប់ថា: "តាយាយទៅដណ្ដឹងគេចុះ ប្រាប់
ថាខ្ញុំអោយមកសុំដណ្ដឹងគេមិនថាអីទេ ។
តាយាយនោះក៏ទៅដណ្ដឹងកូន
ក្រមុំគេ តាមពាក្យចៅប្រី ។

តាយាយ ទៅដល់ផ្ទះអ្នកដែលមានកូនក្រមុំនោះ ក៏ឡើងទៅអង្គុយលើផ្ទះ ។ អ្នកផ្ទះនោះសួរថា: " តាយាយមករកអ្វី ? " តាយាយឆ្លើយថា: " ខ្ញុំមកសូមជំរាបអ្នកលាក់បាំងអីអ្នក ចៅខ្ញុំអោយមកសុំដណ្តឹងកូនក្រមុំអ្នក " ។ ឯម្តាយឪពុកនាងក្រមុំនោះនឹកក្នុងចិត្តថា: " តាយាយនេះម្តេចក៏គាត់ហ៊ានដណ្តឹងកូនអញអោយចៅគាត់? ហើយអ្នកដែលមានកូនក្រមុំនោះនិយាយទៅនឹងតាយាយនោះថា: " តាយាយ! ខ្ញុំអោយ ប៉ុន្តែតាយាយឯងនាំចៅកម្លោះនោះមកអោយយើងមើលសិន បើល្អសមនឹងកូនយើង ៗ អោយមិនថាអីទេ " ។ តាយាយលាគេមកផ្ទះវិញ និយាយប្រាប់ចៅថា: បើចៅឯងល្អសមនឹងកូនគេ គេ អោយ ប៉ុន្តែគេអោយចៅឯងទៅអោយមើលរូបសិន បើសមនឹងកូនគេ ៗ មិនថាអីទេ ។ ឯស្តេចឮតាយាយប្រាប់ដូច្នេះ ក៏មានព្រះទ័យត្រេកអរ សួរទៅវិញថា: " ចុះអោយខ្ញុំទៅថ្ងៃណា? " ។ តាយាយឆ្លើយថា: " ព្រឹកស្អែកយើងនឹងទៅ " ។

លុះព្រឹកឡើង តាយាយនិងស្តេចចៅ នាំគ្នាទៅផ្ទះអ្នកមានកូនក្រមុំនោះ ក៏ឡើងទៅអង្គុយសំពះគេ ហើយថយមកអង្គុយក្នុងទីដ៏សមគួរ ។ អ្នកផ្ទះនោះក៏មានចិត្តស្រឡាញ់កូនប្រសា ប៉ុន្តែមិនដឹងជាស្តេចក្លែងភេទទេ គិតស្មានថាជាមនុស្សផ្តេសផ្តាស ។

ស្តេចនៅបំរើម្តាយក្មេកឪពុកក្មេក រៀងរាល់-ថ្ងៃទៅ ។ វេលាចូលដេក ម្តាយក្មេកប្រាប់កូនស្រីក្រមុំនោះថា: " កូនមាសម្តាយ! ចូរឯងដងទឹកដាក់ចុងជើងប្តី ហើយក្រៀកស្លាប្រាំមាត់ដាក់អោយប្តី ក្រែងជួនយប់ប្តីក្រោកឡើងរកស្លាស៊ី ទឹកផឹក អោយមានស្រាប់ "។ កូននោះក៏ព្រមធ្វើតាមពាក្យម្តាយប្រើ ជួនក៏មិនធ្វើតាម ។ ដល់ថ្ងៃមួយស្តេចភ្ញើជាទៅអូតទឹក ។ ម្តាយក៏ប្រាប់កូនថា: " នាង! ម្តេចមិនយកផ្តិលទៅតាម-ប្តីអូតទឹក ? "។ នាងជាកូនក្រមុំនោះ ក៏ពុំទៅ-តាមពាក្យម្តាយប្រើៗ ស្តេចនោះទៅបរូបនិចក៏វិលមកវិញៗ

ដល់វេលាល្ងាចស្ដេចធ្វើជាផឹកស្រា ស្រវឹងក្អួតក្អែរ ប្រែប្រះខ្លួននៀលពេញល្វែងផ្ទះពុំដឹងខ្លួន ៗ ឯម្ដាយក្មេកឃើញកូនប្រសាស្រវឹងស្រា ក៏ស្ដីប្រាប់កូនក្រមុំថា: " នាងឯងម៉េចមិនយកទឹកទៅលាងកំអួត "ៗ កូនក្រមុំឆ្លើយថា: " ទេមនុស្សអ្វីប្រមឹកស្រាដូច្នេះ ខ្ញុំមិនទៅលាងទេ "ៗ ស្ដេចឮដូច្នោះ ព្រឹកឡើងស្ដេចលាម្ដាយក្មេក ឪពុកក្មេក ទៅផ្ទះយាយចាស់តាចាស់វិញ ប្រាប់តាយាយតាមអំពីដំណើរកូនក្រមុំគេ ដែលយាយតាទៅដណ្ដឹងអោយនោះថា: " តាយាយអើយ! នាងនោះនឹងខ្ញុំមិនបានជាគូរព្រេងសំណាងគ្នាទេ សូមតាយាយទៅប្រគល់កូននោះ អោយគេវិញចុះ ៗ តាយាយទៅជូនព្រេងសំណាងកូនគេ តាមពាក្យចៅប្រើ ទៅដល់លើផ្ទះនិយាយថា: " ខ្ញុំសុំជូនព្រេងសំណាងកូនអ្នកផង ត្បិតចៅថា: " ពុំមានព្រេងនឹងកូនអ្នកទេ "ៗ រួចតាយាយក៏លាមកផ្ទះអាត្មាវិញ ៗ

លុះព្រឹកឡើង ស្ដេចលាតាយាយដើរទៅទៀត ដល់ស្រុកមួយជាចុងស្រុកខេត្តព្រៃ ទៅសុំសំណាក់នឹងផ្ទះដូនចាស់តាចាស់ ៗ ក៏យល់ព្រមស្ដេចក៏នៅធ្វើការរកស៊ីនឹងតាយាយរៀង.រាល់ថ្ងៃតទៅ ៗ ថ្ងៃមួយ ស្ដេចដើរទៅ-លេង បានឃើញកូនក្រមុំអ្នកស្រុក ដែលជាអ្នកមានក្នុងស្រុកនោះ ពុំមានអ្នកណាមានស្មើ ឡើយ អ្នកនោះមានកូនស្រីមួយ កូនប្រុសមួយ ទាំងពីរនាក់បងប្អូនមិនទាន់-មានប្ដីប្រពន្ធទេ ស្ដេចដើរទៅលេងបានឃើញ មានចិត្តគិតចង់បាន លុះវិលមកផ្ទះអាត្មាវិញ និយាយប្រាប់តាយាយថា: " តា ! យាយ ! ខ្ញុំចង់បានកូនគេ ដែលមានកូនប្រុសមួយកូនស្រីមួយ សុំតាយាយទៅដណ្ដឹងកូនគេនោះអោយខ្ញុំផង " ៗ តាយាយឆ្លើយថា: " ចៅអើយបើតាយាយក្រម្ល៉េះ តើនរណាគេនឹងអោយកូនគេមកចៅ " ៗ ឯស្ដេចឮតាយាយនិយាយដូច្នោះ ក៏មានបន្ទូលទៅនឹងតាយាយថា: " សូមតាយាយអញ្ជើញទៅដណ្ដឹងកូនគេចុះ ថាខ្ញុំអោយមកដណ្ដឹងគេមិនថាអីទេ " ៗ



តាយាយនោះ ក៏ព្រមទៅតាមពាក្យចៅប្រើ ប៉ុន្តែយាយ
និងតាពុំដឹងថាចៅនោះជាស្តេចឡើយ គិតស្មានថាមនុស្ស
ធម្មតាដទៃ ក៏ទៅដណ្តឹងកូនគេ គេក៏ព្រមអោយ ៗស្តេច
ក៏នៅបំរើម្តាយក្មេក ឪពុកក្មេកតែសព្វថ្ងៃរៀងទៅ ។

នាងជាប្រពន្ធនោះក៏បដិបត្តិប្តី ល្ងាចដងទឹកដាក់ចុងជើង
រៀបស្លាប្រាំមាត់ដាក់ក្បែរដំណេកប្តីតែរាល់ថ្ងៃរៀងទៅ ។
វេលាស្តេចយាងទៅងូតទឹក នាងកាន់ផ្តិលនិងសំពត់ងូត
តាមទៅផង ។ ពេលស្តេចងូតទឹកនាងនោះដុះក្អែលអោយ
ប្តី ។ ផ្លាស់សំពត់ងូត នាងទទួលយកសំពត់ពូត រួចដង-
ទឹកដាក់ផ្តិលកាន់ដើរតាមប្តីទៅ ដល់ផ្ទះលាងជើងអោយប្តីៗ
ថ្ងៃមួយស្តេចធ្វើជាឈឺ ម្តាយក្មេកឪពុកក្មេកឃើញកូនប្រសា
ឈឺ ក៏មានចិត្តភិតភ័យ ប្រាប់ទៅកូនក្រមុំថាៈ " កូន! មក
មើលគក់ច្របាច់អោយប្តីផង " ។ នាងនោះក៏គក់ច្របាច់អោយប្តី
ប៉ុន្តែស្តេចនិងនាងពុំទាន់រៀបការនៅឡើយទេ ។ ឯឪពុកក្មេកនិង
ម្តាយក្មេកក៏ពុំដឹងជាស្តេចគិតស្មានថាជារាស្ត្រសាមញ្ញ នៅយូរបន្តិច
ទៅ បានវេលាល្អម្តាយក្មេកឪពុកក្មេកនោះ ក៏ចេញប្រាក់របស់ខ្លួន
រៀបការកូនក្រមុំនិងស្តេច ហៅរស់ញាតិជិតឆ្ងាយមករៀបការ

ស៊ីផឹកជាសូរេច ស្តេចនឹងនាងក៏រួមសុខទុក្ខនៅជាមួយគ្នាតាំងពីនោះរៀងមក ។ លុះនៅយូរបន្តិចទៅ ស្តេចចង់ពិសោធចិត្តប្រពន្ធ និងចិត្តម្តាយក្មេក ឪពុកក្មេកអោយឃើញពិត ឬពុំពិត ស្តេចក៏ធ្វើជាផឹកស្រាលេងបៀរចាញ់គេៗ មកទារប្រាក់នឹងរកប្រាក់អោយគេគ្មានៗ ម្តាយក្មេក ឪពុកក្មេក ក៏ចេញប្រាក់អោយរាល់តែថ្ងៃ ទាល់តែអស់ប្រាក់ ធ្លាក់ខ្លួនជាអ្នកក្រ ។ ម្តាយក្មេក ឪពុកក្មេក និងប្រពន្ធនោះពុំមានស្តីថាអ្វី ។ អស់ញាតិសន្តានជិតខាងគេស្រដីថា: " អោយម្តាច់ទៅ កុំអោយកូនទៅអាចង្រៃនេះ វាមិនគិតធ្វើការរកស៊ីដូចគេទាំងពួង វាគិតតែលេងបៀរ ផឹកស្រាដូច្នេះ តើនឹងទុកវាធ្វើអ្វី " ។ គេស្តីប៉ុនគេផ្ទុប់ ម្តាយឪពុកក្មេកក៏មិនអឺះ ។ ឯស្តេចនោះយល់ឃើញថា ម្តាយក្មេក ឪពុកក្មេកក្រលំបាកអស់ទ្រព្យសម្បត្តិមានតែខ្លួនហើយ ក៏ឈប់លេងល្បែង ចេះតែដេកមិនមានគិតរកស៊ីអ្វី ប្រើតែប្រពន្ធអោយធ្វើនំលក់គ្រាន់តែឆ្អែតពោះ ។ ឯម្តាយក្មេក ឪពុកក្មេក ព្រមទាំងប្រពន្ធមិនមានស្រដីអោយធ្ងន់ពាក្យនាំអោយកូនប្រ



ស្តេចទ្រង់នឹកក្នុងព្រះចិន្តាថាៈ " ឱ ចៅបុរសមានប្រាជ្ញយល់ការជ្រៅ ព្រះថាៈ អោយអញរកម្តាយពិត ឪពុកពិត ប្រពន្ធជាស្រីពិត នេះហៅពេញជាត្រូវ ឥឡូវអញរកបានហើយ ល្មមអញតែងព្រះបន្ទូលប្រាប់ទៅសេនាបតីអោយរៀបរាជយាននូវពលថ្មើរជើង តាមមុខងារដំរីសេះរាជរថមកទទួលអញចុះ " ។ ទ្រង់ក៏តែងព្រះបន្ទូលប្រាប់ទៅសេនាបតីមានសេចក្តីថាៈ អោយរៀប ដំរី សេះរទេះ រាជយានពលថ្មើរជើងទៅទទួលស្តេច ត្បិតស្តេចរកប្រពន្ធជាស្រីពិតម្តាយពិត ឪពុកពិតបានហើយ ។ អោយយកគ្រឿងឥស្សរិយ យសទៅថ្វាយជាអាច់ៗ ។ មួយទៀតបើបំរើគាំព្រះបន្ទូលមកដល់ អោយរៀបទទួលជប់លៀង តាមឋានៈជាបងថ្លៃស្តេច ។ ស្តេចតែងរួចស្រេចទ្រង់ដាក់ក្នុងបំពង់ បិទមាត់បំពង់ជិត ពុំអោយបងថ្លៃនោះដឹងសេចក្តី ហើយស្តេចប្រាប់ទៅបងថ្លៃនោះថាៈ " អ្នកបងអើយ ! អញ្ជើញមកអោយខ្ញុំចង់អោយអ្នកគាំសំបុត្រទៅអោយតាហ្នឹន ដែលជាធំនៅក្នុងវាំងហ្លួងនោះ តើអ្នកបងហ៊ានទៅឬទេ ? ៗ



បងថ្លៃព្អូនប្រើគួចោះ ក៏ព្រមទៅតាមហើយចេញដំណើរ ទៅ. សួរគេចប់តែតាមផ្លូវ ទៅដល់ស្រុកមួយ សួរគេ ថា: " អ្នកអើយផ្លូវណាទៅវាំងស្ដេច ? " ។ អ្នកស្រុកប្រាប់ ថា: " ផ្លូវនេះហើយទៅវាំងស្ដេច " ។ បងថ្លៃស្ដេចនោះ ក៏ ចេះតែដើរសួរគេតែរៀងៗទៅ ។ លុះទៅដល់មាត់ទ្វារ វាំង ក៏សួរទៅនាយទាហានយាមទ្វារថា: " អ្នកហ្នឹងហើយ ឬ ដែលគេហៅថាវាំងហ្លួន ? " ។ នាយទាហានប្រាប់ថា "ហ្នឹងហើយ " នាយទាហានសង្ស័យក៏សួរថា: " អ្នកឯង មកពីណា បានជាសួររកវាំងហ្លួន ? " ។ បងថ្លៃស្ដេចឆ្លើយ ថា: " ខ្ញុំនាំសំបុត្រប្អូនខ្ញុំ មកអោយនាហ្មឺនធំដែលនៅក្នុង វាំងនេះ " ។ នាហ្មឺនធំក៏ទទួលយកសំបុត្រ បើកបំពាក់ឡើង អាននឹងសេចក្ដីនៃព្រះបន្ទូលថា: " យើងរកមហេសីជាស្ដ្រី ពិតបានហើយ អោយនាំគ្នារៀបចំទៅទទួលយើង. ឯបំរើ ដែលនាំព្រះបន្ទូលនេះត្រូវជាបងថ្លៃយើង បើបានមកដល់ ចូរអោយអ្នកទទួលរៀបដប់ស្លៀក តាមភាពជាព្រះញាតិ ស្ដេច " ។ នាហ្មឺនធំនោះក៏ចាត់សំបុត្រអោយគេស្មុ អីសេះ

រទេះ រាជយាន ពលថ្មើរជើង តែដោយមុខងារមុខក្រសួងផ្សេងៗ



ឯបងថ្លៃស្តេចក៏ត្រូវគេរៀបចទទួល តាមអោយបែបយ៉ាងជាព្រះញាតិ មានពូកព្រែព្រំខ្មៀម ខ្នល់ខ្នើយ តម្កល់តម្កើងរុងរឿងក្រៃពេក ហើយគេរៀបភោជនាហារសុទ្ធសឹងល្អស្អាងស្អាត ដាក់នឹងភាជន៍មាស លើកយកមកជូនអ្នកជាបងថ្លៃស្តេចដែលនាំសំបុត្រនោះមក ។ ឯអ្នកជាបងថ្លៃស្តេចនោះ ហេតុតែខ្លួនជាអ្នកនៅស្រុកឆ្ងាយពុំដែលស្គាល់ស្តេច ស្ទើរតែពុំហ៊ានបរិភោគភោជនាហារ ដែលជារបស់ល្អថ្លៃនោះឡើយ លុះតែនាហ្មឺនធំគេបង្ខំអោយបរិភោគទើបហ៊ានបរិភោគ តែចាំគន់មើល បើគេបែរមុខចេញ ដៃលួកបន្លំយកនំចំណី លាក់ទុកផ្ញើប្អូនត្បិតខ្លួនមិនដែលបានចំណីល្អបរិភោគ គិតក្រែងស្តេចប្អូនថ្លៃនោះមិនដែលបានដូចខ្លួនដែរ ។ លុះបរិភោគរួច នាហ្មឺននោះតឿនថា: " អ្នកនឿយព្រួយសូមអញ្ជើញសំរាន្តចុះ " ។ អ្នកជាបងថ្លៃស្តេចក៏ស្ទើរពុំហ៊ានដេក ។



លុះព្រឹកឡើង និយាយនឹងនាហ្មឺនថា៖ " ខ្ញុំចង់លាទៅវិញ ត្បិតប្អូនខ្ញុំផ្ដាំថា៖ " បើដល់អោយឆាប់វិលទៅ " ។ នាហ្មឺននោះក៏ចាត់ចែងអោយរៀបភោជនាហារអោយ ។ បរិភោគរួច ក៏លានាហ្មឺនដែលជាធំនោះ ត្រឡប់មកផ្ទះវិញ ។ លុះមកដល់ស្ដេចជាប្អូនថ្លៃសួរថា៖ " ម៉េចអ្នកបង! អញ្ជើញទៅជួបនឹងនាហ្មឺនគេទេ? " ឯបងថ្លៃប្រាប់ស្ដេចជាប្អូនថ្លៃថា៖ " ជួប " ។ ស្ដេចថា៖ " ចុះគេរាប់អានឬទេ? " ។ បងថ្លៃថា៖ " គេរាប់អានបងណាស់ " ។ ស្ដេចឮថានាហ្មឺនគេរាប់អានណាស់ ក៏ទ្រង់ញញឹមៗ ។ ហើយបងថ្លៃនោះ យកនំចំណីដែលលាក់យកមកនោះ អោយស្ដេចប្អូនថ្លៃដោយវាចាថា៖ " នែ៎ប្អូន! បងលាក់នំគេពីវាំងស្ដេចយកមកផ្ញើប្អូន ប្អូនឯងពិសាមើលឆ្ងាញ់ណាស់ " ។ ស្ដេចថា៖ " បងពិសាចុះ " ។ បងថ្លៃថា៖ " ទេ! ប្អូនពិសាមើល " ។ ឯស្ដេចទ្រង់ព្រះតម្រិះថា៖ " បើមិនសោយ ក្រែងបងថ្លៃនោះដឹងថាខ្លួនជាស្ដេច ទ្រង់សោយតែបន្តិចទ្រង់លែងទៅ ទ្រង់ញញឹមថា៖ " ឆ្ងាញ់មែនហើយអ្នកបង " ។



លុះដល់កំណត់៧ថ្ងៃ អស់សេនាបតីមន្ត្រីតូចធំមកជួបជុំទៅទទួលស្តេច រៀបជាក្បួនហែមកដល់ស្តេចគង់នោះ ៗ អស់អ្នកស្រុកក៏ផ្អើលចលាចល់វរល់ភិតភ័យ នាំកូនជញ្ជូនចៅរត់រកទីពួន ដោយគិតស្មានថា: " ទ័ព ពុំដឹងជាគេមកទទួលស្តេចសោះ" ។ លុះនាហ្មឺនគេចូលមកជិតផ្ទះដែលស្តេចគង់នៅនោះ ម្តាយក្មេកឪពុកក្មេកក៏ភិតភ័យ រត់ចូលទៅប្រាប់កូនប្រសា ឯក្នុងផ្ទះថា: " កូនអើយ! ទ័ពមកពីណាច្រើនណាស់ ឬគេមកចាប់កូន ព្បិតកូនទៅលេងល្បៀជំពាក់គេទេដឹងអើយ ? " ។ ស្តេចឮម្តាយក្មេកប្រាប់ដូច្នេះ ក៏ទ្រង់ធ្មីម្នាចេញទៅរានហាលមុខផ្ទះ ។ អស់នាហ្មឺនទាំងពួងមានក្រឡាហោម យមរាជ ចក្រីវាំង ជាដើម ឃើញស្តេចទ្រង់ឈរនៅរានហាល ក៏សុទ្ធតែដើរឱនគោ ៗ ចូលមកក្រាបថ្វាយបង្គំស្តេចរាល់គ្នា ៗ ស្តេចមានបន្ទូលថា:

" អើអស់នាហ្មឺនក្រឡាហោម យមរាជ ចក្រីវាំង សុខសប្បាយរាល់គ្នាទេឬ ? " ។ អស់នាហ្មឺនឆ្លើយព្រមគ្នាថា: " ព្រះករុណាថ្លៃវិសេស សុខសប្បាយជាទេ " ។



ឯម្ដាយរគេក ឪពុកគេក លោកភ្ញាក់ខ្លួនព្រឺត និយាយគ្នាខ្សឹបៗថា: " កូនប្រសាយើងស្ដេចទេតើ " ។ ឯពួកបងប្អូនញាតិសន្ដានដែលនៅជិតខាងក៏ភ្ញាក់ខ្លួនរាល់គ្នា លាន់មាត់ថា: " យីវ៉ឺ លេងមិនបានទេ ស្ដេចទេតើ" ហើយមានចិត្តគិតបារម្ភភិតភ័យតែរៀងខ្លួនឯងក្រែងស្ដេចយកទោស ព្រោះខ្លួនយល់ទាស់មិនចូលចិត្តនឹងស្ដេច ថាស្ដេចចេះតែលេងប៉ៀស៊ីកស្រាមិនរកស៊ី ដល់ដឹងថាស្ដេចក៏ភ័យរាល់គ្នា ។ រស់នាហ៊្មឹនក្រាបទូលសួរស្ដេចថា: " សូមទ្រង់ព្រះមេត្តាប្រោសព្រះរាជទេពីដែលស្ពន់ធ្លុះព្រះបាទថា: " រកបានហើយនោះ តើនៅឯណា ? " ។ ទើបស្ដេចទ្រង់មានព្រះបន្ទូលប្រាប់ថា: " អោយទៅលក់នំលតទៅហើយ រស់នាហ៊្មឹនពួស្ដេចថា " ប្រើទៅលក់នំលតក៏ញញឹមរាល់គ្នា " ។ ហើយក្រាបទូលថា: " ទ្រង់ប្រើទៅលក់នំលតឯណា ?" ។ ស្ដេចទ្រង់មានបន្ទូលថា: " ទៅលក់នំលតនៅភូមិគេខាងជើង" ។ រស់នាហ៊្មឹនបានដឹងដូច្នេះក៏រៀបយានទៅតាម ។



ស្តេចទ្រង់មានព្រះបន្ទូលថាៈ " បើទៅតាមត្រូវមើលតែអ្នកណាពាក់អាវកំបុតដៃ ទូលល្អីចាស់ យួរឆ្នាំងស្ករ ញៀចមាត់ ហ្នឹងហើយប្រពន្ធយើង " ។

នាហ្មឺនទាំងនោះ ក៏ចាត់នាហ្មឺនមួយពួកអោយនាំព្រះរាជយានទៅតាម ជួបនឹងនាងមកពីលក់នំលត ក៏ស្រែកថាៈ "នាងម្ចាស់ឈប់សិន " ។ នាងឮនាហ្មឺនដែលទៅទទួលនាង ស្រែកហៅដូច្នេះ គិតស្មានថាៈ គេមកចាប់ខ្លួន ហើយនាងក៏រត់ចូលព្រៃកាត់តម្រង់មករកផ្ទះ ប្រាក់កាសដែលលក់នំលតនោះក៏ជ្រុះបាត់ខ្លះក្នុងព្រៃទៅ នៅសល់តែបន្តិចបន្តួចដល់មកផ្ទះមើលទៅមុខផ្ទះឃើញមនុស្សច្រើនត្រៀបត្រា គិតថាគេមកចាប់ប្តីទារថ្លៃជំពាក់លេងបៀរគេហើយ នាងក៏រលះរលាំងឡើងទៅសួរប្តីថាៈ " គេមកពីណាច្រើនម្លេះ ? " ។

ស្តេចទ្រង់ប្រាប់នាងថាៈ " គេមកទទួលបងនឹងនាង " ។



ម្តាយហៅកូនទៅឲ្យប្រាប់ថាៈ " ប្តីនាងជាស្តេចទេ-តើ " ។ នាងជាកូនឮម្តាយប្រាប់ ទើបដឹងប្តីជាស្តេច ។

ឯមន្ត្រីដែលតាមនាងវិលមកគាល់ស្តេចៗ ទ្រង់សួរថាៈ " មិនឃើញទេឬ ? " ។ មន្ត្រីទូលថាៈ " ឃើញក្រែងមិនមែន ទូលបង្គំហៅមិនឈប់សោះចេះតែរត់ " ។ ស្តេចមានបន្ទូលថាៈ " មកដល់ហើយ " ។ មន្ត្រីទាំងនោះយកគ្រឿងប្រដាប់សម្រាប់ទ្រង់តម្កល់លើជើងពានមាសលើកយកទៅថ្វាយទាំងទឹកអប់ម្សៅចន្ទន៍ក្លិនពិដោរឈ្ងុយឈ្ងប់ ។ ស្តេចនឹងនាងទ្រង់ស្រង់ព្រះអង្គរួច ទ្រង់ព្រះពស្ត្រស្រួចសង្វារកងកល្អល្អះពេកក្រៃ ។

រួចស្រេចស្តេចនឹងនាងអញ្ជើញម្តាយឪពុកនិងបងប្រុស អោយឡើងជិះដំរី សេះទៅ ។



របស់នាហ្នឹង ក៏ហែរស្តេចទៅចូលព្រះរាជវាំង ដល់ហើយទ្រង់គង់នៅចុងព្រះរាជវាំង ទ្រង់អោយហៅបុរសនោះមកប្រាប់ថាៈ " ចៅបុរសឯងមើលនេះហៅជាស្ត្រីពិត ម្តាយពិត ឪពុកពិត មែនឬមិនមែនទេ? " ។ ចៅបុរសនោះក្រាបបង្គំទូលថាៈ " នេះហៅពេញជាស្ត្រីពិត ម្តាយពិត ឪពុកពិត សូមទ្រង់ជ្រាប " ។ ទើបស្តេចអោយរៀបអភិសេកនាងឡើងជាអគ្គមហេសី ឯបងប្រុសនោះ ទ្រង់តាំងអោយធ្វើជាអគ្គមហាសេនា ម្តាយទ្រង់តាំងជាសម្តេចវររាជជននី ឪពុកទ្រង់តាំងជាសម្តេចព្រះវររាជជនក រួចជាស្រេចស្តេចអោយទៅ យកយាយចាស់តាចាស់ដែលដណ្តឹងនាងច្បាយនោះ មកធ្វើផ្ទះអោយនៅ ហើយទ្រង់អោយចិញ្ចឹមថែរក្សាតទៅ ។



យូរបន្តិចទៅ ស្តេចទ្រង់នឹកភ្នកថាៈ ចៅចុ-
រស់នេះមានគុណានឹងរទ្រៃ ហើយមានប្រាជ្ញាយល់ការ
រាក់ជ្រៅ ស្គាល់លក្ខណៈ ស្រី-ប្រុស ហើយទ្រង់ហៅ
មន្ត្រីមកទ្រង់បង្គាប់អោយសង់រោងការ រអាពាហ៍ពិ-
ពាហ៍ សម្រេចមង្គលផ្សំផ្គុំព្រះរាជបុត្រីនឹងបុរសនោះ
រៀបចំរួចស្រេច ស្តេចទ្រង់អភិសេកបុរសនោះនឹងព្រះ
រាជបុត្រី តាំងអោយជាព្រះមហាឧបរាជ ៗ ក៏នៅជា
សុខសប្បាយតទៅ ៗ

ដល់ស្តេចទ្រង់ព្រះជរា ទ្រង់ដាក់រាជអោយ
មហាឧបរាជ ជាព្រះរាជបុត្រសោយរាជស្នងព្រះអង្គ
រក្សារាណាប្រជានុរាស្ត្រ ជាសុខសប្បាយតទៅ
ហោង ៗ។


២